សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា Free
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

MAYURA
Video . Fashion Jewelry . Hair Clips
978 998 0707 | 978 4558766
ផ្ញើរតាមយន្តហោះ 1ផោន $11
ផ្ញើរតាមកប៉ាល់ 1ផោន $4

21 branch St.
Lowell, MA 01851
Visit us on Facebook : MayuraLowell

## ព័ត៌មានសំខាន់ៗខាងក្នុង...

### នយោបាងអាមេរិកាំង

សូមអានទៅទំព័រទី ០២



### បវរញ្ញាហ្វីលីពីន ខាត្រីណា ”វាយ ហ្វីលីពីន គ្រងមកុដបវរកញ្ញា

សូមអានទៅទំព័រទី ០៣



### រឿងក្ដីនៅសាលាក្រុងឡូវែលស្ដីពី”តំណាងរបស់ជនភាគតិច

សូមអានទៅទំព័រទី ០៦



### Reach Your Educational Goals with MCC's Adult Learning Center

*Please Read Page 09*






ដោយ ពិន សំខុន

ឆ្នាំថ្មី ចម្រើនអាយុ១ឆ្នាំថែមទៀត សម្រាប់ប្រទេសជាតិ គេគិតតែពីការរីកចំរើនពុំចេះចប់ ចំណែកឯមនុស្សគឺការខិតទៅរកទីបញ្ចប់កាន់តែខ្លី, ក៏ប៉ុន្តែការរីកចំរើននៃប្រទេសនោះ ក៏បានចូលរួមបង្កើនអាយុមនុស្សកាន់តែវែងទៅហើយដែរ អាយុ១០០នៃចុងបញ្ចប់របស់មនុស្សទូទៅបានកើនទៅជាអាយុ១២០ទៅហើយ ។ អាយុកាន់តែវែងតើមកពីយើងមិនបានកសាងអ្វីសោះ មែនទេ?

មិនមែនទេ! មួយឆ្នាំថែមថ្មីមួយទៀតនេះ ទាំងប្រទេសជាតិទាំងមនុស្សជាតិ គឺយើងបានប្រឹងប្រកួតនឹង”អវិជ្ជា-អ្វីដែលយើងមិនដឹង”ប្រកួតជាវិជ្ជមានមិនបានឈប់ទេ, ពីព្រោះតែរៀងរាល់ថ្ងៃនៃដំណើរប្រក្រតីទិន មនុស្សតែងតែរកឃើញនូវ”អ្វីដែលមិនដឹង”នោះ បានជាចំណេះថ្មីមកទៀតជារៀងរាល់ថ្ងៃមកដែរ ។សូមពិនិត្យមើលទៅក្រោយឱ្យឆ្ងាយ! អ្វីដែលព្រះពុទ្ធជាម្ចាស់លោកបានរកឃើញនៅក្នុងសម័យ”សម្មាសម្មាធិ”របស់ព្រះអង្គកាលពី២៥០០ឆ្នាំមុននោះ ឥឡូវនេះវិទ្យាសាស្រ្ត ឬចិត្តវិទ្យាបានរកឃើញធាតុពិតរបស់វា ហើយពិសោធន៏បានទៀតផង... ពិភពដែលព្រះលោកយាងទៅដល់នាពេលមុន ក៏សម័យបច្ចុប្បន្ននេះ ក៏អាចបញ្ជូនមនុស្ស ឬសត្វទៅដល់បានរួចទៅហើយ មនុស្សបានឈ្នះលើធម្មជាតិរាប់មិនអស់ ដូចជាអាចទប់ស្កាត់មិនឱ្យស្លាប់នឹង រងារឬក៏ក្ដៅ អាចហោះហើរបានដូចសត្វបក្សាបក្សី, អាចទទួលព័ត៌មានរហ័សទាន់ចិត្ត ដូចផ្លេកបន្ទោរឬរន្ទះ ដូច្នោះដែរ... ការផ្ចាញ់មារ ដោយអាវុធប្រល័យក្រុងលង្កា ក៏សម័យក្រោយមកនេះអាវុធបរមាណូប្រល័យលោក ក៏មានមនុស្សមានអំណាចក្ដោបក្ដាប់ សម្រាប់ត្រួតត្រាគ្នាមិនខ្វះទេ -ពេលវេលាចេះតែទៅមុខ អវិជ្ជាក៏ចេះតែថយ តើឆ្នាំថ្មី២០១៩នេះនឹងក្លាយទៅជាអ្វីទៀត? យើងថ្ងូរពីភាព”អវិជ្ជមាន”ជាច្រើនមែន, តែពីភពលោកនៅតែទៅមុខដ៏ដែល... តើដោយសារអ្វីទៅ?

តទៅទំព័រទី ០៤

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ


978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

ការិយាល័យ មេធាវី
ថំមាស ស្ទាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

# នយោបាយអាមេរិកាំង

នាចុងឆ្នាំ២០១៨នេះ លោកប្រធានាធិបតី "ឌូណល ត្រម" កំពុងមានការខ្វល់ខ្វាយច្រើនប្រការៈ ១-ចំពោះអំណាចសភាដំណាងរាស្ត្រដែលទើបនឹងធ្លាក់ក្នុងដៃ របស់គណបក្សប្រជាធិបតេយ្យកាលពីខែវិច្ឆិកាកន្លងទៅ ២-នយោបាយរបស់លោកមិនបានចុះសម្រុងជាមួយនឹងគណបក្សសាធារណរដ្ឋរបស់លោក ច្រើនចំណុច ដែលលំបាកឱ្យមានការគាំទ្រពេញទំហ៊ឹងពីគណបក្សរបស់លោកផ្ទាល់ ៣-ប្រជាប្រិយភាពរបស់លោក"ត្រម"កំពុងតែធ្លាក់ចុះយ៉ាងខ្លាំង ហើយមានឈ្មោះថា ជាប្រធានាធិបតីពូកែរភូតភរ មិនទាន់ដឹងថា តើលោកនឹងអាចគេចផុតពីការទាញទំលាក់ពីដំណែងដែរឬទេ? នៅបន្តិចទៀតនេះ។

នយោបាយក្រៅប្រទេសរបស់លោក ក៏កំពុងតែបង្កើតសត្រូវ នឹងការមិនទុកចិត្តពីប្រទេសសម្ព័ន្ធមិត្ត ស្ទើរតែទាំងអស់ - ហើយនៅនាទីចុងក្រោយបង្អស់នេះ លោកសម្រេចដកទ័ពអាមេរិកាំងចេញពីប្រទេសស៊ីរីយា ប្រឆាំងនឹងយោបល់ទីបញ្ជាការកងទ័ពអាមេរិកាំង ហើយដែលធ្វើឱ្យរុស្ស៊ីរីករាយនឹងការដកទ័ពនេះជាទីបំផុត ពីព្រោះទុកតំបន់ដ៏គ្រោះថ្នាក់នេះ ឱ្យទៅរុស្ស៊ីធ្វើអ្វីបានតាមអំពើចិត្ត។

នៅដើមឆ្នាំ២០១៩ គេអាចទាយទុកបានថា "លោកត្រម"នឹងប្រឈមមុខនឹងបញ្ហាជាច្រើន ទាក់ទងទៅនឹងបទបញ្ជាប្រតិបត្តិដែលនឹងត្រូវគាំងដំណើរ នៅពេលសុំសេចក្តីទុកចិត្តពីសភាមិនបាន ហើយដំបូងគេបង្អស់នេះ លោកត្រម បានសុំកញ្ចប់



ឌូណល ត្រម

ថវិការ៦ពាន់លាន ដើម្បីទៅសង់ជញ្ជាំងនៅទល់ដែន"ម៉ិកស៊ិក" តែសភាដំណាងរាស្ត្របានឱ្យដឹងថាៈ គេអនុញ្ញាត្តិ១៣០០លានទេ ដែលធ្វើឱ្យលោក"ត្រម" អាក់អន់ចិត្តជាខ្លាំង ហើយចង់បិទដំណើរការរដ្ឋាភិបាលថែមទៀត។ តទៅទំព័រទី ០៩

# នយោបាយកម្ពុជា

ចាប់តាំងពីកម្ពុជាបានបោះឆ្នោតចុងក្រោយរួចមក កក្កដា២០១៧ -ក៏បានក្លាយជាប្រទេសដែលមាននយោបាយឯកបក្ស (សមាជិកសភា ១២៥រូប មកពីគណបក្សប្រជាជនតែមួយ) ក៏បណ្តាលឱ្យមានការក្បៀបសង្កត់សេដ្ឋកិច្ចនឹងនយោបាយ



ហ៊ុន សែន

ពីសំណាក់ប្រទេសមហាអំណាចខាងលិច មានអឺរ៉ុប អាមេរិក កាណាដា អូស្ត្រាលី យ៉ាងដំណំ។ គេបានចោទប្រកាន់ថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបំពានរំលោភលើសន្ធិសញ្ញាក្រុងប៉ារីស ឆ្នាំ១៩៩១ ដោយរកលេសគ្រប់យ៉ាងមករំលាយគណបក្សប្រឆាំង ហើយចាប់អ្នកនយោបាយប្រឆាំង ព្រមទាំងសមាជិកអង្គការសិទ្ធិមនុស្សជាច្រើនដាក់ពន្ធនាគារ ដោយគ្មានភស្តុតាងគ្រប់គ្រាន់។ ចាប់ពីពេលនោះមកលោក ហ៊ុន សែន បានបញ្ជាតុលាការបញ្ជាអង្គការសភាជាតិ នឹងអង្គការព្រឹទ្ធសភា ដើម្បីធ្វើវិសោធនកម្មលើច្បាប់ ដកហូតដំណែងមេឃុំនឹងចៅសង្កាត់ ដែលជាប់ឆ្នោតមកពីបក្សប្រឆាំង ដើម្បីមិនឱ្យធ្វើនយោបាយបានទៀតផង។ កាសែតឯករាជ្យដូចជា The Cambodia Daily នឹង PhnomPenh post បានត្រូវបង្ខំឱ្យបិទទ្វារ លែងមានសារពតិមានឯករាជ្យនៅកម្ពុជាតទៅទៀតទេ។

ការរំលោភសិទ្ធិមនុស្សបំបិទសេរីភាពនឹងបំផ្លាញស្ថាប័នប្រជាធិបតេយ្យដ៏ធ្ងន់ធ្ងរនេះ បានត្រូវសហគមន៏អន្តរជាតិកាត់ជំនួយសេដ្ឋកិច្ចកាត់ជំនួយអភិវឌ្ឍន៏ ថែមទាំងគម្រាមបិទទិដ្ឋាការបង្កកប្រាក់ដុល្លា ដល់មន្ត្រីដែលបានធ្វើឱ្យខូចលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាទៀតផង។ សមាជិកគណបក្សប្រឆាំងជាច្រើន បានរត់ចេញមកក្រៅ ប្រទេសបន្តធ្វើសកម្មភាពដោយមិនព្រមទទួលស្គាល់ តទៅទំព័រទី ០៩



# បវរកញ្ញាហ្វីលីពីន ខាត្រីណា ៉រាយ ហ្វីលីពីន ត្រងមកុដបវរកញ្ញាចក្កវាឡឆ្នាំ ២០១៨




ប្រទេសថៃ- បវរកញ្ញាចក្រវាលឆ្នាំ ២០១៨ រឺMiss Universe 2018 បាននាំស្រ្តីមកពីគ្រប់ទិសទីជាង៩៤ ប្រទេសឱ្យចូលរួមការប្រកួតដ៏ធំបំផុតមួយនេះនៅលើពិភពលោក។ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨នេះ មានការផ្សាយបន្តផ្ទាល់ចេញពីមជ្ឈមណ្ឌល Impact Arena នៅទីក្រុងបាងកក ក្នុងការស្វែងរកម្ចាស់មកុដ ដោយមានការចូលរួមពីពិធីករថ្មីមាត់បែបកំប្លែងរបស់អាមេរិក គឺលោក ស្ទេវ ហារី ព្រមទាំងតារាម៉ូដែល អាស្លី ក្រាហាម ផងដែរ។

ជាលទ្ធផលនោះគឺ បវរកញ្ញាមកពីប្រទេសហ្វីលីពីនមានឈ្មោះថា ខាត្រីណា ៉រាយ (Catriona Gray) អាយុ២៤ឆ្នាំ បានដណ្តើមបានពានរង្វាន់បវរកញ្ញា Miss Universe 2018 នៅប្រទេសថៃ។ក្នុងការប្រគួតនោះដែរបវរកញ្ញាអាហ្វ្រិកខាងត្បូង តាមារីន គ្រីន (Tamaryn Green) គឺជាប់ក្នុងចំណាក់ថ្នាក់ first runner-up និងចំណាត់ថ្នាក់បន្ទាប់គឺបានទៅលើប្រទេសវេនីស៊ូអេឡា កញ្ញា ស្តេហ្វិនទី គូតេរេស (Sthefany Gutiérrez) Cab;Ca second runner-up ។

ក្នុងការប្រគួនេះក៏មានការចូលរួមពីតំណាងកម្ពុជាផងដែរ គឺកញ្ញា រឿន ស៊ីណាត ដែលមាន




អាយុ២៧ឆ្នាំមកពីខេត្តកំពង់ចាម។ កញ្ញា ស៊ីណាត បានឱ្យកាសែតភ្នំពេញប៉ុស្តិ៍ដឹងកាលពីថ្ងៃទី១៨ ខែធ្នូនេះថា "មានការអាត់អន់ស្រពុនចិត្តបន្តិចបន្តួច តែមានស្មារតីល្អ"។ ក្នុងពេលដំណើរការនៃការប្រគួតកញ្ញា ស៊ីណាត មានការលំបាកមួយចំនួនជាពិសេសគឺផ្នែកភាសា ដោយសារកញ្ញាពិបាកក្នុងការនិយាយទំនាក់ទំនង តែស៊ីណាតអាចស្តាប់យល់ភាសាអង្លេសបាន។ កញ្ញាបានថ្លៃថា "វាល្អនៅពេលដែលមានអ្នកអ្នកបកប្រែនៅជិតដើម្បីបញ្ជូនសារនូវអ្វីអ្នកចង់ចែករំលែកឱ្យបានត្រឹមត្រូវ... ប៉ុន្តែខ្ញុំគិតថា វាមិនអាចធ្វើឱ្យការប្រកួតប្រជែងកាន់តែងាយស្រួលសម្រាប់បេក្ខជនទេ"។

កញ្ញា រឿន ស៊ីណាត បានមានប្រសាសន៏ថា "បវរកញ្ញាទាំងអស់ដែលចូលរួម Miss Universe ឆ្នាំ ២០១៨ គឺពួកគេល្អនឹងខ្ញុំ។ យើងបានចែករំលែកបទពិសោធន៏ដ៏អស្ចារ្យជាមួយគ្នា ហើយខ្ញុំនឹងដឹងគុណជានិច្ចដោយដឹងថា ឥឡូវនេះខ្ញុំមានមិត្តភក្តិមកពីផ្នែកផ្សេងៗនៃពិភពលោក។ សម្រាប់ពេលនេះ កញ្ញា ស៊ីណាត នឹងត្រឡប់មកប្រទេសកម្ពុជាវិញ និងបន្តបំរើការជាមួយនឹងជនរងគ្រោះដោយសារជំងឺអេត និងយុវជនដែលងាយនឹងគ្រោះដោយសាគ្រឿងញៀន។


## មកទេសចរណ៍រដូវស្លឹកឈើជ្រុះនៅតំបន់ម៉ារីម៉ាក់វ៉ាលេ

ក្រាន់តែធ្វើដំណើរតែកន្លះម៉ោងប៉ុណ្ណោះពីទិសពាយព្យនៃទីក្រុងប៊ូស្តុននឹងមកដល់តំបន់ម៉ារីម៉ាក់វ៉ាលេ។ការផ្លាស់ប្តូររដូវកាលបន្ថែមនៅភាពរស់រើកនៅតំបន់នេះ។

មានថាមពលអស្ចារដែលមិនអាចប្រកែកបាននៅតំបន់ ម៉ារីម៉ាក់វ៉ាលេ ដែលថាមពលដូចគ្នានេះដែលបានផ្តល់កំណើតដល់ប្រទេសរបស់យើង។ ក្រុងនិមួយក្នុងចំណោម ក្រុង និងទីប្រជុំជនទាំង 12 របស់យើងមានសម្រស់ និងទីកន្លែងប្លែកពីគេដែលលោកអ្នកត្រូវការ,

ដំណើរកម្សាន្តបន្ទាប់របស់លោកអ្នករង់ចាំលោកអ្នកនៅទី

















Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

merrimackvalley.org

សូមចូលទៅកាន់ Twitter និង Instagram @MerrimackValley

តមកពីទំព័រទី ០១

## ត្រៀមខ្លួនសម្រាប់ប្រជែងគ្នានៅ...

គឺដោយសារតែការរីកចំរើន និងជឿនលឿនទាំងឡាយនោះ អាចទ្រទ្រង់ភាពរស់រានមានជីវិតចីរកាលបាន ក៏ព្រោះតែមានការផ្សារផ្ជាប់នឹងសេចក្តី "ល្អ-បរិសុទ្ធ -វិជ្ជមាន" ។ ចំពោះជីវិតនឹងចិត្តមនុស្សសត្វ រួមនឹងពិភពដែលខ្លួនរស់នៅ តែងពឹងផ្អែកទៅលើៈ រុក្ខជាតិ ដំណាំ ព្រឹក្សា លតាវល្លិ បឹងបួរ ទន្លេ សមុទ្រ យ៉ាងជិតស្និត របស់ទាំងនោះ "កើតនឹងរលត់"ដូចពុទ្ធឱវាទមែន ។ ក្នុងពុទ្ធោវាទនោះ កំហឹង អំណាចផ្តាច់ការ ការលោភលន់... ទាំងនោះវានាំមកនូវការ"រលត់... ជាប្រភពសម្រាប់សម្លាប់មនុស្សសត្វ" ច្រើន ឬតិចទៅតាមទំហំនៃប្រភពនោះ -សារជាតិពុលពិស ឬការបំផ្លាញធ្វើឱ្យបាត់បង់លំនឹងបរិស្ថានធ្វើឱ្យបាត់បង់ជីវិតនៃធម្មជាតិ បាត់បង់រុក្ខជាតិ ចុងបញ្ចប់ គឺបណ្តាលឱ្យបាត់បង់ម្ហូបចំណីដែលចិញ្ចឹមជីវិតមនុស្សនោះឯងទៅវិញ ។ ប៉ុន្តែ...ពូជពង្សដែលតវង្សត្រកូល រាប់មិនអស់មកដល់សព្វថ្ងៃ គឺជាជង្រុកនៃការខិតខំក៏សាងអំពើ"ល្អ-បរិសុទ្ធ" ថែរទាំជីវិតឱ្យបានគង់វង្ស ក៏សាងតំបន់សន្តិភាព តំបន់មានការគ្រប់គ្រងកាពារជីវិតរក្សាបរិស្ថានមានគម្រោងគ្រប់គ្រងជីវិតយូរអង្វែង ទើបមានជីវិតរីកចំរើនរហូតមកដល់សព្វថ្ងៃនេះបាន... គឺការកើត តែងមានច្រើនជាងរលត់ ពីព្រោះតែការ"កសាង"តែងឈ្នះនូវការ"វិលាយ"ជាធម្មតា ។ សាសនាជាច្រើន ដែលមានវត្តមានរហូតមកដល់សព្វថ្ងៃ ធ្លាប់បានផ្តល់ឱវាត ផ្តល់គំនិត ផ្តល់មធ្យោបាយ អប់រំមនុស្សឱ្យចេះរស់ប្រសើររស់មានអនាម័យរស់មានសីលធមិបានធ្វើឱ្យមានមនុស្សជាច្រើនជឿលើសេចក្តី"ល្អ -បរិសុទ"តាំងពីច្រើនសតវត្សមកហើយ -ចំណែកឯសាសនាដែលបំផ្លាញជីវិតមនុស្ស ដែលគ្មានសីលធមិ ក៏គ្មានមនុស្សជឿ ហើយក៏រលាយសាបសូន្យទៅដែរ។ ហេតុដូច្នេះហើយ បានជាមនុស្សសត្វ តែងស្រឡាញ់ ពេញចិត្ត លើអំពើល្អ ចំពោះគ្នាទៅវិញទៅមកចង់ឱ្យអ្នកដ៏ទៃរស់នៅដោយរីករាយ សុខសប្បាយ សង្គមនោះក៏ប្ញីកដុះដាល ធាត់ធំបាន... ផ្ទុយទៅវិញ អំពើអាក្រក់ ច្រណែននិន្ទាឈ្នានីស ផ្តាញ់ផ្តាល គៀបសង្កត់ តែងតែទទួលវិវការស្អប់ មិនចូលចិត្ត សងសឹក ឈ្លោះប្រកែកធ្វើឱ្យសង្គមនោះរួមតូចទៅៗ ជាលំដាប់ រហូតដល់រលាយខ្លួនបាត់ទៅហោង។

មិនថារូបគេឬយើង "ខ្លាំងឬមានអំណាច ឬមានសម្បត្តិ"ប៉ុណ្ណានោះទេ អ្នករកស៊ី អ្នកនយោបាយ អ្នកស្រែចំការ... លោកអ្នក "នឹងរីកចំរើនដុសដាល" ឬក៏ "ខូចខាត ស៊ិយស្សៀវ គ្មានសំណាង" ទាំងនោះវានៅលើមាគ៌ាដែលខ្លួនឯងបានជ្រើសរើសតែប៉ុណ្ណោះ ។ សូមឱ្យឆ្នាំចាស់បញ្ចប់ទៅដោយយកអំពើបាបកម្ម មិនស្មោះត្រង់ ទុក្ខសោក ទៅជាមួយឱ្យអស់... ហើយសូមឱ្យឆ្នាំ២០១៩ប្រកបតែសេចក្តីល្អបរិសុទ្ធ ស្រឡាញ់រាប់អានគ្នាយ៉ាងស្មោះស្ម័គ្រទៅវិញទៅមក ដើម្បីសេចក្តីចំរើន សុខសប្បាយ រួចរំដោះពីក្តីទុក្ខលំបាក ទាំងអស់គ្នា។


**KhmerPost USA, LLC**
**សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អគ្គនាយក សុបិន្ត ពិន



Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធ ខ្មែរ Khmer Editorial



និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy

ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng



**មណ្ឌលពិនិត្យសុខភាពលីន LYNN PRIMARY CARE CENTER**
**វេជ្ជបណ្ឌិត សុខារិទ្ធ មី DR. SOKHARITH MEY, MD**
**(781) 780-7755**








**មានទទួលអ្នកជំងឺថ្មី**

**Now Accepting New Patients**
Family Medicine for Men, Women, and Children
Behavioral Health - Individual and Group Counseling
Evening & Weekend hrs available
We accept MassHealth, Medicare and other health insurances
Our staff speak Khmer

**280 Union St. Unit 402 Lynn, MA 01901**
ផ្នែកជំងឺទូទៅ សំរាប់បុរស ស្ត្រី និងកុមារ
ផ្នែកជំងឺផ្លូវចិត្ត ផ្តល់ប្រឹក្សាមួយទល់មួយនិងជាក្រុម
ក្រុមគ្រូពេទ្យមានបទពិសោធន៍ជាច្រើនឆ្នាំ
ធ្វើការបំរើសុខភាពក្នុងសហគមន៍ខ្មែរ ទីតាំងល្អនិងមានចំណតរថយន្ត
ឥតគិតថ្លៃ បើកពេលយប់ និងចុងសប្តាហ៍


Boch Honda West
299 Littleton Rd, Westford, MA 01886
EXIT 32 - OFF 495
Happy Honda Days
SALES EVENT
ធ្វើដំណើរជុំវិញពិភពលោក 8 ដង
ហើយលោកអ្នក នៅតែមានការការពារ
HOME OF THE 20 YEAR 200,000 MILE LIMITED POWERTRAIN
★ WARRANTY ★
BOCH Honda West
HONDA
រួមបញ្ចូលជាមួយនឹង
រាល់ការទិញរថយន្តហុងដា ថ្មី
ដោយមិនគិតថ្លៃបន្ថែមទៀតឡើយ!
ការសន្សំដ៏ច្រើនសម្រាប់ការផ្តល់ជូនថ្ងៃចុងក្រោយក្នុងឆ្នាំ២០១៨
2018 Honda
CIVIC LX
MANUAL SEDAN
តម្លៃជួល
$69
ក្នុងមួយខែសម្រាប់ 24 ខែ
2018 Honda
ACCORD LX
AUTO SEDAN
តម្លៃជួល
$104
ក្នុងមួយខែសម្រាប់ 24 ខែ
2018 Honda
CR-V EX
AWD
តម្លៃជួល
$189
ក្នុងមួយខែសម្រាប់ 24 ខែ
2019 Honda
PILOT LX
AWD
តម្លៃជួល
$243
ក្នុងមួយខែសម្រាប់ 24 ខែ
សម្រាប់ព័ត៌មានបន្ថែម
ទំនាក់ទំនង នីកូល ឈុន : nchhun@bochhondawest.com
គ្រូវការបុគ្គលិកផ្នែកលក់
ទំនាក់ទំនងមកកាន់ ខេរិន ជេជ : kcregg@bochhondawest.com
Boch Honda West .com | (978) 252-2125
HONDA

# រឿងក្តីនៅសាលាក្រុងឡូវែលស្តីពី“តំណាងរបស់ជនភាគតិច”ដល់ណាហើយ?

ដោយ ពិន សំខុន

រឿងក្តីនៅតុលាការស្តីពី"ដំណាងជនភាគតិច" សម្រាប់តំបន់និមួយៗនៅក្រុងឡូវែល គឺរឿងដែលបានចាប់ផ្តើមកាលពី៣-៤ឆ្នាំមុន នៅតែបន្តដូចរឿងភាគកុនចិន មិនចេះចប់នៅឡើយ ថ្វីត្បិតតែលោកសមាជិកក្រុមប្រឹក្សាក្រុង"ប៊ួតនីយ អេលីយ៉ុយ"ខិតខំឆ្លីសកកាយឱ្យឆេះឡើងវិញ ច្រើនដងមកហើយក្តី។ នេះជាឱកាសចុងឆ្នាំ២០១៨ យើងជា"អ្នកភូមិ"របស់ក្រុងយើង ក៏គួរតែដឹងថា"រឿងមួយនេះវាទៅដល់ទីបញ្ចប់ដែរឬទេ?"

រឿងនេះបានប្តឹងឡើងនៅពេលអង្គការក្នុងតំបន់មួយឈ្មោះ"មេធាវិសម្រាប់សិទ្ធិពលរដ្ឋ" និយាយថា បានប្តឹងក្រុងឡូវែល ពីព្រោះតែ"បានរំលោភរដ្ឋធម្មនុញ្ញនៃសហរដ្ឋ ដោយមិនព្រមបង្កើតឱ្យតំបន់និមួយៗ មានតំណាងផ្ទាល់ម្នាក់របស់គេ"។ នៅក្រុងឯទៀតៗ ដែលនៅជុំវិញឡូវែល គេបានប្តូរស្ថានភាព"តំបន់"ឱ្យស្របរដ្ឋធម្មនុញ្ញអស់ទៅហើយ តែ"ឡូវែល"មិនទាន់បានធ្វើនៅឡើយទេ -មកទល់ថ្ងៃនេះ "ឡូវែល"មានតំណាងរបស់ខ្លួន៩រូប ដែលជាប់ឆ្នោតដោយការបោះឆ្នោត"សាកល -At Large" គឺបានន័យថា"សមាជិកក្រុមប្រឹក្សាក្រុង១រូប ជាតំណាងឱ្យឡូវែលទាំងមូល ឬក៏សមាជិកទាំង៩រូប ក៏ជាតំណាងឱ្យតំបនទាំង៧នៃឡូវែល"ដែរ -តែរដ្ឋធម្មនុញ្ញនិយាយថា"តំបន់និមួយៗ ត្រូវតែមានដំណាងម្នាក់របស់ខ្លួន ។

សម្រាប់ស្ថានភាពសព្វថ្ងៃឡូវែលពុំមានតំណាងសម្រាប់តំបន់និមួយៗទេ ការដែលមានខ្មែរ-អាមេរីកាំងម្នាក់ដែរ គឺលោក"វ៉ាស្នា នួន" ដែលឈរជាតំណាងឱ្យសហគមន៍ខ្មែរនៅឡូវែលដែរ តែមិនស្ថិតស្ថេរទេ ដោយសារមិនដំណាងឱ្យ "ហាយឡិន"តែ១ដ៏សម្បូរខ្មែររស់នៅនោះទេ។ ធាតុពិតនៃសមាសភាពនៃសមាជិកក្រុមប្រឹក្សាក្រុងសព្វថ្ងៃ គឺចែកជា៖៧នាក់ មកពីតំបន់ "បែលវីឌ្យែ" រីឯ២រូបទៀតមកពីតំបន់ផ្សេង -ហេតុអ្វីក៏មានរឿងយ៉ាងនេះ? គេសរសើរថា "បែលវីឌ្យែ" ស្រុះគ្នា៧០%គេចេញទៅបោះឆ្នោត តែគេបន្ទោសថា ខ្មែរនឹងជនភាគតិចឯទៀតៗ មិនស្រុះគ្នា មានតែ២០%ប៉ុណ្ណោះទៅបោះឆ្នោតដូច្នេះក្រុងឡូវែលទាំងមូលត្រូវបានគ្រប់គ្រងដោយតំបន់"បែលវីឌ្យែ" តែមួយយ៉ាងនោះហើយ។

តើធ្វើយ៉ាងដូចម្តេច ដើម្បីជៀសវាងកុំឱ្យ "ឡូវែលទាំងមូល"គ្រប់គ្រងដោយ"តំបន់តែ១" នោះបាន? ដោយសារតែបណ្តឹងនោះ នឹងដោយសារតែការរំលឹកជាញឹកញយដោយ"រ៉តនីយ អេលីយ៉ុត" មានបំណងមួយបានលេចចេញមកពីក្រុមប្រឹក្សា គឺត្រូវត្រៀមប្តូរច្បាប់បែងចែកភាពជា



ក្រុមប្រឹក្សាសាលាក្រុងឡូវែលទាំង៩រូប



លោក រ័ត្ននីអ៊ីលីយ៉ុត

តំណាងតំបន់នៅឡូវែលនេះ - តើគេនឹងបែងចែកយ៉ាងណា? មានការប្រជុំមួយរបស់សមាជិកក្រុមប្រឹក្សាក្រុង កាលពីសប្តាហ៍មុន ដើម្បីធ្វើសំណើរឱ្យមានការបែងចែកមួយ មុននឹងតុលាការសម្រេចជុំនួស! គំនិតជាមូលដ្ឋាននោះ គឺ"មិនត្រូវឱ្យតំបន់ណាមួយមានប្រៀបទៅគ្រប់គ្រងតំបន់ឯទៀតបានទេ!" ដូច្នេះត្រូវបង្កើតឱ្យមាន"District representation ដោយសេចក្តីត្រូវការនឹងចាំបាច់ ។

លោក រ៉តនីយ អេលីយ៉ុត បានស្នើរទៅសមាជិកក្រុមប្រឹក្សា គួរឱ្យមាន"District -តំណាងតំបន់ចំនួន៦" នឹងដំណាងសម្រាប់ឡូវែលទាំងមូល" At Large - ដំណាងសាកល២រូប" ធ្វើយ៉ាងនេះនឹងពុំមាននរណាគ្រប់គ្រងលើតំបន់ផ្សេងបានឡើយ តែឡូវែលពុំទាន់សម្រេចយករូបមន្តនោនៅឡើយទេ ដោយគេរង់ចាំការចរចាជាមួយ"ក្រុមមេធាវី" ដើមបណ្តឹងនៅពេលខាងមុខនាដើមឆ្នាំក្រោយ, អ្នកដែលចង់រង់ចាំនោះ ទំនងជាមានបំណងរក្សាអំណាចដែលខ្លួនយកបានមកហើយឱ្យនៅគង់វង្សបានយូរបន្តទៅទៀត។ គេបានដឹងថា តុលាការគេកំពុងតែរង់ចាំ ការស្របយោបល់គ្នា រវាងអ្នកដើមបណ្តឹងនឹងសាលាក្រុងសេចក្តីសម្រេចបញ្ចប់នឹងធ្វើនៅខែកញ្ញា២០១៩។

ការគ្មានដំណាងតំបន់និមួយៗ"District representation"នេះហើយ ដែលជាញឹកញយ គេពុំឃើញមានសមាជិកក្រុមប្រឹក្សាជាខ្មែរ នៅសាលាក្រុង ដ៏សម្បូរខ្មែររស់នៅនោះទេ - ហើយនៅក្រុងដ៏សម្បូរជនភាគតិចរស់នៅមានស្បានីសមានជនអាហ្វ្រិកាំង តែដំណាងរបស់គេ ពុំមែនជាជនភាគតិចទាំងនោះដែរ ។ នៅឡូវែលប្រជាពលរដ្ឋខ្មែរអាមេរិកាំង ដល់ទៅជាង៣០% រស់នៅនឹងរស់ស៊ីប្រកបដោយភាពជោគជ័យ តែពុំមាននរណាការពារផល់ប្រយោជន៍ពួកគេពិតប្រាកដទេ។

ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

We make health care easy.
Neighborhood has affordable plans for:
• Children and families
• Individuals
• Small businesses
យើងធ្វើឲ្យការថែទាំសុខភាពងាយស្រួល
Neighborhood មាន គម្រោងដែលមានតម្លៃសមរម្យសម្រាប់៖
• កុមារ និងក្រុមគ្រួសារ
• បុគ្គលម្នាក់ៗ
• អាជីវកម្មខ្នាតតូច
Neighborhood Health Plan OF RHODE ISLAND™
Contact us today to learn more!
សូមទាក់ទងមកយើងខ្ញុំនៅថ្ងៃនេះ ដើម្បីស្វែងយល់បន្ថែម!
www.nhpri.org



# DIVERSITY

## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

# ឡូវែល: ចាស់ៗមិនបានត្រូវតែបំភ្លេចទេ

ដោយខ្មែរផុសស.រ.អា

នៅចុងឆ្នាំ២០១៨នេះ យើងបានចូលទៅសួរសុខទុក្ខបងប្អូនចាស់ទុំនៅ"Adult Day Care - មណ្ឌលរក្សាសុខភាពមនុស្សពេញវ័យពេលថ្ងៃ"មួយដែលមានឈ្មោះថា "Active Day"នា ៣៤៥ Chelmford St. Lowell, MA 01851 គឺជាអាគារឥដ្ឋក្រហមជំនាន់ចាស់ដ៏ធំល្វឹងល្វើយមួយដែលគេជួសជុលឡើងថ្មីស្រឡាងមកវិញ។ នាព្រឹកថ្ងៃចន្ទទី១៨ វេលាម៉ោង១១ យើងមានសេចក្តីរីករាយ នឹងបានឃើញចាស់ៗអាយុប្រមាណជា៥០-៦០ឆ្នាំ ប្រហែលជា៧០នាក់ កំពុងរាំលេងជាមួយគ្នា ឬក៏រាំលេងកំសាន្តដោយល្បែងដែលអាចលេងច្រើនគ្នាបាន ឬក៏រាំលេងនឹងបរិភោគចំណី"ស្នាក់"... ក្នុងបរិយាកាសប្រកបដោយសេរីភាពនឹងសុខភាពប្រសើរតែរៀងៗខ្លួន។

គួរឱ្យចម្លែកដែរ ដែលជាទូទៅ ស្ត្រីឬក៏បុរសចំណាស់ តែងតែជួបគ្នាពេលណា ហើយអួតគ្នាតែពី"អាការរោគ" ទៅវិញទៅមក ដោយសារតែជម្ងឺប្រចាំរាងកាយនៃមនុស្សចាស់ តែព្រឹកនេះ ទាំងអស់គ្នាទំនងជាមិនមានអំនួតរបៀបនោះតទៅទៀតទេ គេមានកម្លាំងកំហែង ពីព្រោះគេកំសាន្តយ៉ាងរីករាយរាក់ទាក់ ខ្លះប្រកួតគ្នានឹងកូនអុកលើក្តារចត្រង់តាំងពីច្រើនឆ្នាំមកហើយ ខ្លះទៀតគេមានទាំងនាំគ្នាហាត់"ក្បាច់គុណចិន-តាយជី"ទៀតផង... ភាពជាយុវវ័យបានត្រឡប់មកវិញ ជាមួយនឹងកម្មវិធី ដែលនាំឱ្យមានការថែទាំនឹងយកចិត្តទុកដាក់ពិសុខភាព ដល់រូបរាងកាយ ប្រឆាំងនឹងភាពទ្រុឌទ្រោមនៃជីវិត។

អ្នកស្រីប្រធានជំរុំដ៏ស្រស់ស្អាត ឈ្មោះ"ខេរី គ្គោជេ"អ្នកខ្លះ ហៅថា"ម៉មេ ឬក៏ អ្នកម្តាយ"ជាអ្នកទទួលខុសត្រូវក្នុងមជ្ឈមណ្ឌល ក្នុងការផ្តល់នូវកម្មវិធីប្រចាំថ្ងៃដល់ភ្ញៀវជាមនុស្សពេញវ័យជាទីស្រឡាញ់របស់អ្នកស្រី។ អ្នកស្រីនិយាយថា "ភ្ញៀវទាំងអស់បានក្លាយទៅជាគ្រួសារតែមួយទៅហើយ ដោយសារតែខ្ញុំបានផ្តល់ជូនមិនត្រឹមតែអ្វីដែលស្របនូវសេចក្តីត្រូវការរបស់មនុស្ស នឹងរបស់សុខភាពទេ គឺមានទាំងស្របតាមវប្បធម៌របស់ភ្ញៀវថែមទៀត គឺយើងមានម្ហូបអាហារ ដែលរៀបចំតាមចំណូលចិត្ត នឹងតាមតម្រូវការសុខភាព ចំអិនដោយចុងភៅនៃភោជនីយដ្ឋានឯកទេសខ្មែរ យើងមានដូចជាល្បែងលេង ភ្លេង ចម្រៀងខ្មែរ រួមទាំងពិធីសាសនានានា ដែលជាទំនៀមទំលាប់មាននិមន្តព្រះសង្ឃមកចូលរួមតាមពិធីសាសនាខ្មែរផង"។

អ្នកស្រី ផល្លី ជាភ្ញៀវម្នាក់បានសម្តែងការជាប់នឹងពេញចិត្តជាខ្លាំង ចំពោះមជ្ឈមណ្ឌល ដែលបានផ្តល់នូវការផ្លាស់ប្តូរដល់សុខភាពផ្លូវកាយនឹងផ្លូវចិត្តដល់រូបលោកស្រី តាំងតែពី៩ខែមកហើយដែលអ្នកស្រីមកដល់ទីនេះ។ ថ្វីត្បិតតែអ្នកស្រីមានអាយុជាង៧០ឆ្នាំទៅហើយក្តី រូបរាងស្គមសមរមតែរហ័សរហួន និយាយភាសាបារាំង អង់គ្លេស នឹងខ្មែរយ៉ាងចំណានជាមួយនឹងយើងអ្នកស្រីនិយាយថា"តាំងតែពីប្តីអ្នកស្រីតែស្លាប់ទៅអ្នកស្រីនៅផ្ទះមានកូនចៅច្រើន តែងតែធ្វើឱ្យមានកង្វល់ច្រើនឈឺក៏ច្រើន ដល់មកដល់ទីនេះ ខ្ញុំរីករាយច្រើន សុខភាពក៏ប្រសើរ មានមិត្រភក្តិក៏ច្រើន តែឥតទាន់មានសង្សារថ្មីទេ... ខ្ញុំចូលចិត្តជួយយកអាសារគេណាស់ តែមិនចូលចិត្តរាំលេងទេ ពីព្រោះកាន់សាសនាគេអ្នកស្រីមិនឱ្យយើងរាំសប្បាយពេលទេ"។

អ្នកស្រី ខេរី បន្តថា"យើងមានកម្មវិធីក្នុងផ្ទះហើយក៏មានកម្មវិធីចេញដើរកំសាន្តខាងក្រៅជាញឹកញាប់ដែរ...ដូចជាទៅកំសាន្តសួនឱទ្យានទៅលេងសមុទ្រនាខែក្តៅ ពេលខ្លះជូនទៅដើរផ្សារ ក៏មាន..." នៅពេលសួរថា តើមជ្ឈមណ្ឌលមានអ្នកព្យាបាលជម្ងឺសម្រាប់ភ្ញៀវរបស់ខ្លួនដែរឬទេ? ខេរីឆ្លើយថា"យើងមានគិលានុបដ្ឋាកដែលឃ្លាំមើលសម្ពាធឈាម,មើលម្ហូបអាហារដែលជួយដល់សុខភាពពួកគាត់ តែបើមិនស្រួលខ្លួន មានក្តៅខ្លួនឬឡើងឈាមខ្លាំង យើងជាអ្នកហៅរកគ្រូពេទ្យផ្ទាល់ខ្លួនជូន ឬក៏យើងមានអ្នកជូនទៅពេទ្យ ឬទៅសង្គ្រោះបន្ទាន់ បើមានការចាំបាច់... ទីនេះគឺជាផ្ទះទី២របស់ពួកគាត់..."។

យើងបានឃើញចាស់ៗ ចូលចិត្តមកអង្គុយស្តាប់ គ្រូពេទ្យពន្យល់ពីអាការៈជម្ងឺ, ខ្លះទៀតក៏នៅបន្តកំសាន្តនូវអ្វីដែលខ្លួនចូលចិត្តធ្វើមិនមកស្តាប់ទេ... យើងបានជួបបុគ្គលិកឈ្មោះ បុផ្ផា ជាអ្នកគ្រប់គ្រងកម្មវិធីកំសាន្តប្រចាំថ្ងៃ ដែលភ្ញៀវទាំងអស់អាចចូលរួម យ៉ាងរវល់ មមាញឹក តាំងពីព្រឹក រហូតដល់រសៀល ពេលទៅផ្ទះវិញ- ពេលយប់មិនមានភ្ញៀវនៅតទៅទៀតទេ។

មជ្ឈមណ្ឌលរក្សាសុខភាពមនុស្សពេញវ័យនេះ មិនយកកម្រៃពីភ្ញៀវទេ តែមានថវិការមកពី"Insurance អង្គការធានារ៉ាប់រងសុខភាព"ដែលភ្ញៀវម្នាក់ៗតែងតែមានប្រចាំខ្លួន ។ មជ្ឈមណ្ឌលមានកិច្ចសន្យាជាមួយក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់ភ្ញៀវ ហើយសន្យាថែរទាំសុខភាពមនុស្សចំណាស់ពី៥៥ឡើងទៅ ឱ្យបានទៀងទាត់ នឹងឱ្យបានប្រសើរ -ដែលធ្វើរបៀបនេះ នឹងធ្វើឱ្យភ្ញៀវទទួលបាននូវសុខភាពផ្លូវកាយនឹងចិត្តបានល្អឡើងវិញ ហើយធ្វើយ៉ាងនេះ គឺបន្ថយការព្យាបាលនៅមន្ទីរពេទ្យ បានយ៉ាងច្រើនដងផង, ពិសេសទៅទៀតចាស់ៗខ្មែរយើងនៅឡូវែលនេះ ប្រាកដជាមានសំណាងខ្ពស់ ពីព្រោះ"មានអ្នកថែរទាំ ដូចជាកូនថៃម៉ែ ឪ នៅផ្ទះខ្លួន"ដូច្នោះដែរ"។


ហាត់តែជី



អ្នកស្រី ផល្លី


ស្តាប់គ្រូពេទ្យនិយាយពីជំងឺ




បុប្ផា និង ខេរី កូជេ

# Reach Your Educational Goals with MCC's Adult Learning Center

## មជ្ឈមណ្ឌលសិក្សារបស់មមនុស្សពេញវ័យ

សាលាបង្រៀនមនុស្សពេញវ័យ ដើម្បីត្រៀមចូលមហាវិទ្យាល័យដោយមិនមានយកកំរៃ (សម្រាប់មនុស្សពីអាយុ១៦ឆ្នាំឡើងទៅ ដែលរស់នៅនឹងធ្វើការនៅរដ្ឋម៉ាសាឈូសេត) ។ យើងទទួលចុះឈ្មោះចាប់ផ្តើមពីថ្ងៃពុធ ទី២ ខែមករាឆ្នាំ២០១៩ទៅ ។

-មានរៀនពេលថ្ងៃពីម៉ោង០៩ដល់១២:៣០



នាទីថ្ងៃអង្គារ៍ ដល់ថ្ងៃព្រហស្បត្តិ៍ ។

-ពេលល្ងាចពីម៉ោង៦ដល់ម៉ោង៩ ថ្ងៃច័ន្ទ-ថ្ងៃពុធ ទូរស័ព្ទ 781-280 3662 ឬ 978-941-1373

The Middlesex Community College Adult Learning Center (ALC) offers FREE noncredit college-preparation courses for adult learners (ages 16 and up) who live and work in Massachusetts. Students are admitted throughout the school year, on a space-available basis. The next registration period begins Wednesday, Jan. 2, 2019.

"Our experienced and professional instructors help returning-adult students develop and improve their computer, study and job skills," said Kathy Innis, ALC Director. "The program helps prepare students for success in college, at work, and in the community."

ALC classes are small and range from adult basic-educationto preparation for the High School Equivalency credential (GED or HiSET).

Day classes meet from 9 a.m. to 12:30 p.m. Tuesday through Thursday on the Bedford campus, 591 Springs Road.

Evening classes meet from 6. to 9 p.m. Monday and Wednesday, at McDevitt Middle School, 75 Church St., in Waltham. Classes are held September through May.

Classroom instruction in reading, writing, mathematics, science, social studies and basic computing/digital literacy skills is provided. Students have access to computer labs with specialized software to supplement classroom learning. The Adult Learning Center is a free program supported by a grant from the Massachusetts Department of Elementary and Secondary Education.

For more information about MCC's Adult Learning Center, visit www.middlesex.mass.edu/adultlearning. For questions about daytime classes, call 781-280-3662. For questions about evening classes, call 978-941-1373.

## តមកពីទំព័រទី ០២ នយោបាយអាមេរិកាំង

ជាលទ្ធផល នាចុងឆ្នាំ២០១៨នេះ ពលរដ្ឋអាមេរីកាំង មានកាងារធ្វើច្រើនជាងមុនមានលុយចាយច្រើនជាងមុន រកស៊ីក៏កាកកបជាងមុនមែន, តែពលរដ្ឋនៅមានបញ្ហានឹងការធានាសុខភាពមានបញ្ហានឹងអន្តោប្រវេសន៏ នឹងជំនួយដល់ប្រជាជនក្រីក្រ ។

## តមកពីទំព័រទី ០២ នយោបាយកម្ពុជា

ការរំលាយបក្សពីសំណាក់គណបក្សប្រជាជនទេ ។ ចំណែកឯអង្គការសហប្រជាជាតិ នឹងសហគមន៏អាស៊ាន មិនបានសម្តែងការមិនទទួលស្គាល់របប ហ៊ុន សែន នោះទេ តែគេកត់សំគាល់ទំនាក់ទំនងរវាងប្រទេសបានចុះអូនថយដោយការមិនទទួលលោក ហ៊ុន សែន ឱ្យពេញមុខជានាយករដ្ឋមន្ត្រីខ្មែរតែប៉ុណ្ណោះ ។

នាចុងឆ្នាំ២០១៨នេះ ដោយសារតែយោធានិយមដោយខ្វះព័តិមានភាពខ្លាចរអើល ប្រទេសកម្ពុជា ផ្តើមស្ងប់ស្ងាត់ពីបាតុកម្ម ពីកូដកម្ម បង្កឡើងដោយការសម្តែងឆន្ទះរបស់គណបក្សប្រឆាំង ហើយប្រទេសចិន ក៏ចូលមកជួយជាវិនិយោគបំពេញចរិការខ្វះខាតជួយជាសប្បុរសជនដល់កម្ពុជា ធ្វើឱ្យរដ្ឋបាលលោក ហ៊ុន សែន មានភាពឯករាជ្យពីជំនួយលោកខាងលិចបានច្រើនដែរហើយ ។ ទាំងនេះមិនមែនបានន័យថាខ្មែររួចខ្លួនទេ គឺលោក ហ៊ុន សែន បានបរិច្ចាកអធិបតេយ្យភាពមួយចំណែកទៅឱ្យចិនដោយឱ្យដីវិនិយោគកំពុងផែយោធានៅកោះកុងនឹងមួយចំណែកទៀតទៅឱ្យវៀតណាម ដោយឱ្យប្រជាជនវៀតណាមរស់នៅវិនិយោគដោយគ្មានត្រួតពិនិត្យ នៅភាគខាងកើតនឹងខាងជើងនឹងទន្លេសាបនៃប្រទេសកម្ពុជា ។

នៅពេលដែលលោក ហ៊ុន សែន យកប្រធានគណបក្សតូចៗនៅភ្នំពេញទៅធ្វើជាមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល, ខាងគណបក្សប្រឆាំងដ៏ធំ នៅក្រៅប្រទេសឯណោះវិញ គឺគណបក្សសង្គ្រោះជាតិបានប្រមូលអ្នកគាំទ្របានច្រើនពាន់សែននាក់ ប៉ុន្តែបែរជាបានចែកគ្នាជា២ក្រុមដាច់ពីគ្នា គឺក្រុមលោក សម រង្សី មួយនឹងក្រុម កឹម មនោវិទ្យា - ពៀម ប៉ុញ្ញាឬទ្ធិ មួយទៀត, តែគោលដៅទំនងជាដូចគ្នាគឺរំលំរបប ហ៊ុន សែន តែមួយ ។ ចំណែកនៅក្នុងប្រទេសវិញ លោក កឹម សុខា ប្រធានសង្គ្រោះជាតិនៅជាប់ឃុំក្នុងផ្ទះឯក្រុងភ្នំពេញនៅឡើយ ។





MIDDLESEX Community College
BEDFORD • LOWELL
Student Success Starts Here

# Discover YOUR Path

MCC started me on the path to...

Self-discovery and growth

With **14 degree and certificate programs**, for students interested in the health field, MCC can help you earn a degree, begin a bachelor's degree or upgrade your skills.

*Share YOUR Path with us! #MCCpath*

CLASSES START JAN. 22 **Register Today!**

- Nationally accredited programs
- Expert faculty
- Small-class environment
- State-of-the-art labs
- Hands on skills practice
- A price you can afford



www.middlesex.mass.edu/discover



## REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH

COST EFFECTIVE NEWSPAPER ADVERTISING




**PUBLISHING**
Two Issues Every Month

**READERSHIP**
50,000 Monthly
600,000 Annually

**Khmer Post USA Distribution Locations:**

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

| | |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 7 Oct and 21 |
| 6 May and 20 | 9 Nov and 23 |
| 10 Jun and 24 | 6 Dec and 20 |

*Advertising deadlines are 5 business days prior to printing date.*

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

www.khmerpost.us



# Red Rose

ភោជនីយដ្ឋាន RESTAURANT

កុលាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិន ខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm



បាយសាច់ជ្រូកពងទាចៀន







* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400



# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិជាសាមីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**
- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***
- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***
- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed
## for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

LCCPS
LOWELL COMMUNITY
CHARTER PUBLIC SCHOOL



ACHIEVEMENT • LEADERSHIP • EXCELLENCE



No Tuition - *We are a Public School!*
Support for ELL & Special Needs
Extended School Day & Year
Gifted & Talented Program
Extended Day Program

Info Session:
January 17th @5:30PM
February 5th @9:00 AM
APPLY ONLINE TODAY!

NOW ACCEPTING APPLICATIONS! 2019-2020
206 Jackson Street • Lowell MA 01852 • (978) 323-0800 • www.lccps.org

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្ដីអន្តរាយដល់បុគ្គល
- ច្បាប់ធានារ៉ាប់រង
- សំណងបុគ្គល
- ការរំលោភបទព្រហ្មទណ្ឌ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បំណុលអចលទ្រព្យ
- បណ្ដឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com



CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ័ម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ដោយសារតែ

# Health Connector

មនុស្សរាប់ពាន់នាក់ស្វែងរកផែនការណ៍ធានារ៉ាប់រង
សុខភាពសំបូរបែបក្នុងតម្លៃទាប ឬឥតគិតថ្លៃ

## អ្នកមានការធានា!



MASSACHUSETTS HEALTH CONNECTOR
យើងខ្ញុំភ្ជាប់ទំនាក់ទំនងអ្នកទៅនឹងការថែទាំសុខភាពរបស់អ្នក!

ការចុះឈ្មោះបើកទូលាយនឹងបញ្ចប់ថ្ងៃទី២៣ ខែមករា ហើយគឺជាពេលវេលាប្រចាំឆ្នាំដែលត្រូវធានារ៉ាប់រងសុខភាព ឬទិញផែនការថ្មីមួយសម្រាប់ឆ្នាំបន្ទាប់

**ការធានារ៉ាប់រងដែលមានគុណភាពខ្ពស់**

ផែនការសុខភាពរបស់ Health Connector ទាំងអស់រ៉ាប់រងលើអត្ថប្រជន៍សំខាន់ៗ ដែលរួមមាន៖

- ការជួបពិនិត្យជាមួយវេជ្ជបណ្ឌិត
- សេវាសង្គ្រោះបន្ទាន់
- សេវាស្តារនិតិសម្បទាឡើងវិញ
- ការព្យាបាលបង្ការនិងសុខមាលភាព
- ការចូលសំរាកព្យាបាលនៅមន្ទីរពេទ្យ
- ការប្រើប្រាស់ឱសថតាមវេជ្ជបញ្ជា
- ការធ្វើតេស្តនៅមន្ទីរពិសោធន៍
- សុខភាពផ្លូវចិត្តនិងការប្រើប្រាស់គ្រឿងញៀន
- ការថែទាំពេលមានផ្ទៃពោះនិងទារកទើបនឹងកើត

ត្រូវការជំនួយក្នុងការចុះឈ្មោះ ? សូមទៅកាន់មជ្ឈមណ្ឌលក្នុងតំបន់របស់អ្នក៖

Boston
133 Portland Street
Boston, MA 02114

ចូលមើល www.MAhealthconnector.org ឬទូរស័ព្ទទៅលេខ: 1-877-623-6765 | TTY 1-877-623-7773

## ការិយាល័យច្បាប់

រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រូវប៊ុណ្ណា តាំង

Law Office of
**Rosa & Taing**
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com

LEGEND
## MOTOR GROUP, INC.

**ហាងជួលជុសរថយន្ត លេជេន**

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?

**ទូរស័ព្ទ 978-458-2085**

COLLISION REPAIR

BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។

**115 Rock St. Unt #7 Lowell, MA 01854**

# ជួបបញ្ហាបង់ថ្លៃកម្តៅ?

## កម្មវិធីជំនួយឥន្ធនៈអាចជួយអ្នកបាន!*

*អាចមានលក្ខខណ្ឌខ្លះ

រាល់ឆ្នាំអង្គការ Community Teamwork ផ្តល់ជំនួយឥន្ធនៈដល់១២,០០០លំនៅដ្ឋាន ដែលជួបបញ្ហា ដោយសារចំណាយច្រើនលើថ្លៃកម្តៅ





COMMUNITY TEAMWORK

| ទំហំគ្រួសារ | ប្រាក់ចំណូល |
|---|---|
| 1 | $ 35,510 |
| 2 | $ 46,437 |
| 3 | $ 57,363 |
| 4 | $ 68,289 |
| 5 | $ 79,215 |
| 6 | $ 90,141 |

### សូមទាក់ទងដើម្បីណាត់ជួប

សូមទាក់ទងដើម្បីណាត់ជួប
ទូរស័ព្ទលេខ៖ ៩៧៨ ៤៥៩ ៦១៦១
អ៊ិនធើណិត៖ www.commteam.org
ចុចលើពាក្យ Fuel Assistance ពណ៌ខៀវ នៅលើគេ ខាងស្តាំដៃ

ជំនួយនេះផ្តល់តាមសហគមន៍ដូចខាងក្រោម

Arlington, Bedford, Belmont, Billerica, Burlington, Carlisle, Chelmsford, Dracut, Dunstable, Groton, Lexington, Lowell, Pepperell, Tewksbury, Tyngsboro, Waltham, Watertown, Westford, Wilmington

ការផ្សព្វផ្សាយនេះ គឺមានការជួយឧបត្ថម្ភពីកម្មវិធីជំនួយផ្នែកថាមពលសម្រាប់គ្រួសាមានចំណូលទាបតាមរយៈថវិការដែលបានមកពីក្រសួងអភិវឌ្ឍន៍សហគមន៍ និងលំនៅដ្ឋានម៉ាសាឈូសេត។

# ActiveDay

## The Brighter Side of Caring

**Active Day Adult Day Health of Lowell** is accepting new members and applicants to join our staffing team!

Active Day of Lowell ផ្តល់ជូនសមាជិករបស់ខ្លួននូវ៖

- ការដឹកជញ្ជូនដល់កន្លែងទទួលសេវា និងកន្លែងណាត់ជួប
- អាហារបែបខ្មែរដែលមានរស់ជាតិឆ្ងាញ់
- ការមើលថែទាំដល់កន្លែង និងបុគ្គលិកជំនួយការគិលានុបដ្ឋាយិកាដើម្បីជួយបំពេញតំរូវការផ្នែកសង្គម, សុខភាព, និងការគាំពារ ហើយក៏មានផ្តល់ការអប់រំសុខភាព
- សកម្មភាពនៅនឹងកន្លែង និងបុគ្គលិកផ្នែកសេវាសង្គម ដើម្បីផ្តល់ការថែទាំ, សកម្មភាពសប្បាយៗ, ការហាត់ប្រាណ, ការរបៀបចំព្រឹត្តការណ៍ប្រចាំខែ និងការធ្វើដំណើរក្នុងសហគមន៍ដើម្បីឲ្យសមាជិករក្សាកាយសម្បទាម៉ាំមួន និងទំនាក់ទំនងជាមួយសង្គមខាងក្រៅ!
- កម្មវីធីបែបសាសនាព្រះពុទ្ធ ដោយព្រះសង្ឃគង់នៅវត្តនៅឡូវែល
- បុគ្គលិកនិយាយភាសាខ្មែរដែលទាក់ទាក់, រួសរាយ និងមានការយល់ដឹងពីតំរូវការបែបសាសនា និងវប្បធម៌

យើងខ្ញុំកំពុងធ្វើការពង្រីកក្រុមការងារគិលានុបដ្ឋាយិកា, ជំនួយការគិលានុបដ្ឋាយិកា, អ្នកបើកបរ និងអ្នកស្ម័គ្រចិត្តនិយាយភាសាខ្មែរ!

ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ចូលរួមជាសមាជិក រឺដាក់ពាក្យមុខតំណែងណាមួយ ដើម្បីចូលរួមជាមួយក្រុមការងាររបស់យើង សូមទូរស័ព្ទទៅកាន់នាយកមជ្ឈមណ្ឌល លោក ខេរី កាឌី តាមលេខ 978-596-111 សម្រាប់ព័ត៍មានលំអិត រឺអ៊ីម៉ែលប្រវត្តិរូបរបស់អ្នកទៅកាន់ KGauthier@activeday.com!